**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ នេះព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាពនៅព្រះរាជាណាចក្រជប៉ុន

-អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ប្រារព្ធពិធីបុណ្យមាឃបូជា តាមប្រពៃណីព្រះពុទ្ធសាសនា នៅបរិវេណព្រះមហាសក្យមុនីចេតិយនាភ្នំព្រះរាជទ្រព្យ

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តសុវណ្ណមុនីសាគរ (ហៅវត្តសំរោងអណ្ដែត)

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធឧទ្ទិសភូមិអភិវឌ្ឍន៍សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ចុកត្រាច ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-អនុញ្ញាតឲ្យឯកឧត្តម William A-Heidt ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យគណៈប្រតិភូគណៈកម្មាធិការសិទ្ធិមនុស្ស នៃសហភាពអន្តរសភា (IPU)ចូលជួបសម្ដែងការគួរសម



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អនុញ្ញាតឲ្យនាយកមូលនិធិ**ខុនរ៉ាដ អាដិនណៅអ៊ែរ** ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ

-អញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីស្ថានទូត និងជនរួមជាតិខ្មែរមកពីសហរដ្ឋអាមេរិក

-អញ្ជើញនាំយកបច្ច័យទេយ្យវត្ថុ អង្ករ គ្រឿងឧបភោគ បរិភោគ ប្រគេនសម្ដេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្ដេចសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបទុមវត្តី

-អញ្ជើញពិសារអាហារពេលល្ងាចរួមជាមួយសមាជិក សមាជិកាគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ដែលត្រូវអញ្ជើញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រជប៉ុន តាមការអញ្ជើញរបស់ឯកអគ្គរាជទូតជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅនិវេសនដ្ឋានឯកអគ្គរាជទូត

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៥ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលការកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភា

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមបដិសណ្ឋារកិច្ចជូនដំណើរសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រជប៉ុន

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងបានផ្ដល់ផ្លូវលំមួយខ្សែជូនប្រជាពលរដ្ឋ នៅឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២៥ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងកិច្ចប្រជុំ

ពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមបដិសណ្ឋារកិច្ចជូនដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រជប៉ុន

-អញ្ជើញជាអធិបតីបើកវេទិកាថ្នាក់ខេត្តស្តីពី**លើកកម្ពស់ និងជំរុញការអភិវឌ្ឍន៍ឃុំ-សង្កាត់** នៅសាលប្រជុំសាលាខេត្តបាត់ដំបង

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ក្នុងឱកាសដែលក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមទៅពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ នៅឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក:**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០១ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភាៈ

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

២.ពិនិត្យ និងសម្រេចលើរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភា ឆ្នាំ២០១៥

៣.ពិនិត្យ និងសម្រេចលើគម្រោងប្រើប្រាស់កញ្ចប់ថវិកាឆ្នាំ២០១៦ របស់ព្រឹទ្ធសភា

៤.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តប្រជុំលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គចំនួន០១លើក** :

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកុម្ភៈនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ

ព្រឹទ្ធសភាជាមួយនឹងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

-គណៈកម្មការពិសេស ប្រជុំពិនិត្យពិភាក្សាអំពីការរៀបចំសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន១៦ករណី ផ្ញើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៦ករណី ទទួលលិខិតឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំវេទិកាថ្នាក់ខេត្តស្តីពី**លើកកម្ពស់ និងជំរុញការអភិវឌ្ឍឃុំ-សង្កាត់** នៅខេត្តបាត់ដំបង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ភូមិភាគទី២ ភូមិភាគទី៥ ភូមិភាគទី៦ ប្រជុំពិភាក្សាអំពីគម្រោងរៀបចំវេទិកានៅស្រុកបាភ្នំ ខេត្តព្រៃវែង នៅខណ្ឌទួលគោក រាជធានីភ្នំពេញ និងត្រៀមចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាននៅខេត្តកែប ខេត្តកំពត និងខេត្តត្បូងឃ្មុំ

-ប្រជុំអន្តរគណៈកម្មការ ដើម្បីពិនិត្យរបាយការណ៍បូកសរុបការងាររយៈពេល០១ឆ្នាំរបស់ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា ជាមួយសភានៃបណ្តាប្រទេស (វៀតណាម ឡាវ ចិន ជប៉ុន និង បារាំង) និងក្រុមការងារអន្តរសភា ( IPU AIPA APF CLV APA និង APPF)និងធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៤ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) នៅប្រទេសកាណាដា

-ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើគម្រោងរៀបចំសិក្ខាសាលាស្តីពីហេតុផលដែលនាំឲ្យមានការលំបាកក្នុងការអនុវត្តក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ

-ប្រជុំជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីបញ្ហាបទបញ្ញា និងនីតិវិធីចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦

-ប្រជុំពិភាក្សាជាមួយបេសកជនកូរ៉េចំនួន៤០នាក់ ស្តីពីការរកជំនួយមនុស្សធម៌ជួយប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា នៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្ត

សៀមរាប

-ជួបពិភាក្សាការងារជាមួយអង្គការ UNESCO ពីគម្រោងរៀបចំសិក្ខាសាលាស្តីពីបេតិកភណ្ឌវប្បធម៌អរូបីនៅកម្ពុជា

-អនុញ្ញាតឲ្យលោកស្រី **Mireille EZA** នាយិការគម្រោង NORIA នៃសភាប្រើប្រាស់ភាសាបារាំង APF និងលោក **ដារ៉ារិទ្ធ គឹមយាត** ប្រធានវិទ្យាស្ថានសភាកម្ពុជា PIC ចូលជួបពិភាក្សាការងារ

-អនុញ្ញាតឲ្យគណៈប្រតិភូជប៉ុន ដឹកនាំដោយលោក **Takashi Fujihashi** អគ្គនាយកក្រុមហ៊ុន Fujihashi ដែលជាក្រុមហ៊ុនរកស៊ីផ្នែកកសិកម្ម និងកសិឧស្សាហកម្ម នៅប្រទេសជប៉ុន ចូលជួបពិភាក្សាការងារដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគនៅកម្ពុជា

-ជួបសវនាការជាមួយលោកស្រី **Wan Hea Lee** តំណាងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ស្តីពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា

-ជួបពិភាក្សាការងារជាមួយតំណាងអង្គការសុខភាពពិភពលោក (WHO) អំពីប័ណ្ណសមធម៌ និងប្រធានអង្គការសម្ព័ន្ធភាពអាស៊ីសិទ្ធិលំនៅឋាន និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍ប្រចាំនៅប្រទេសថៃ

-ស្តាប់បទបង្ហាញរបស់វិទ្យាស្ថានសភាកម្ពុជា (PIC) ចំពោះឯកសារទស្សនទានពាក់ព័ន្ធនឹងប្រធានបទនៃអង្គវេទិកានៅខេត្តបាត់ដំបង និងបញ្ហាផ្សេងៗ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១៥៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្សការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៦លើក។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ម៉ុង ឫទ្ធី** ឯកឧត្តម **ឈិត គីមយាត** និងលោកជំទាវ **លី នារី** អញ្ជើញអមដំណើរ**សម្តេចវិបុលសេនា ភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រជប៉ុន

-ឯកឧត្តម **ប៊ូ ថង** បានដឹកនាំគណៈប្រតិភូគណៈកម្មការទី៤ ព្រឹទ្ធសភា អញ្ជើញធ្វើទស្សនកិច្ចការងារនៅគណៈបញ្ជាការដ្ឋានសន្តិសុខជាតិតំបន់ TAY NGUYEN នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **សួន រ៉ាន់ឡេង** អញ្ជើញចូលរួមប្រជុំស្តីពីការដោះស្រាយបញ្ហាប្រឈមដ៏សំខាន់ក្នុងពេលបច្ចុប្បន្ន តួនាទីរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងអង្គភាពផ្អែកទៅលើជំនឿដោយអង្គការ UPF នៅសាធារណរដ្ឋកូរ៉េ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ